ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 04 / 05 / 2016
ម៉ោង (Time/Heure): 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

002/19-09-2007-ECCC/TC
E1/405

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ ចន្ទ ទី ២១ ខែ មីនា ឆ្នាំ ២០១៦

## សវនាការលើភស្តុតាង - ថ្ងៃ ៣៨៦

រៀបចំដោយ៖ **ឯម ហ៊ុយ** និង Matthew J. McCARTHY

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា , ចៅក្រម Claudia FENZ |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី , ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោក ឯម ហ៊ុយ, លោក Matthew J. McCARTHY |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Dale LYSAK, Vincent De Wilde d' ESTMAEL, លោក ស្រ៊ា រតនៈ |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អរុណ, លោក លីវ សុវណ្ណា |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSÉ |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |

| | |
|---|---|
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Marie GUIRAUD, លោកស្រី ស៊ីន សុវ៉ិន, លោកស្រី ទី ស្រ៊ីនណា, លោកស្រី ជេត វណ្ណលី, , លោក វ៉ែន ពៅ |
| ដើមបណ្ដឹង/សាក្សី/អ្នកជំនាញ៖ (2-TCW-900) |
| មេធាវីប្រឹក្សា៖ ម៉ម រិទ្ធា |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី សួ សុទ្ធាវី |
| ផ្សេងៗ៖ លោក កែវ វ៉ាត, លោក ឡូញ ង៉ែត ,កញ្ញា សុក សុភ័កមុនីកា, លោកស្រី ពេជ ចរិយា, លោក ឡាយ ណារា, កញ្ញា Hannah KIM , លោក Lachlan SLATTERY |

**ពេលវេលាទូទៅរបស់តុលាការ៖**

| | | |
|---|---|---|
| ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ | ចាប់ផ្ដើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៦.០៩ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.១៣ | បញ្ចប់ម៉ោង៖ ១០.៣៣ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៣៥ | បញ្ចប់ម៉ោង៖១៣.៣៣ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤៣ | បញ្ចប់ម៉ោង៖ ១៥.០១ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៥ ម៉ោង និង ២៨ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៥ | ០៩.០៨ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.០៨ | ០៩.១១ |
| សេចក្ដីសម្រេចផ្ទាល់មាត់ស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ | អង្គជំនុំជម្រះ | ០៩.១១ | ០៩.១២ |
| សំណើរបស់សហព្រះរាជអាជ្ញាដើម្បីស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-1016 និងសាក្សី 2-TCW-1017 | សហព្រះរាជអាជ្ញា<br><br>សហមេធាវីនាំមុខ<br>មេធាវីការពារក្ដី នួន ជា<br>មេធាវីការពារក្ដី ខៀវ សំផន | ០៩.១៤<br>០៩.៣៣<br>០៩.១៩<br>០៩.២០<br>០៩.២៣ | ០៩.១៨<br>០៩.៣៩<br>០៩.២០<br>០៩.២៣<br>០៩.៣៣ |

| | | | |
|---|---|---|---|
| | | ០៩.៣៩ | ០៩.៤២ |
| ការតាំងសំណួរទៅកាន់សាក្សី (2-TCW-900) | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា | ០៩.៤២<br>០៩.៥៣<br>១០.៣៤<br>១៣.៣៣ | ០៩.៥៣<br>១០.១៣<br>១១.៣៥<br>១៦.០៧ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ សាក្សី 2-TCW-900 មានវត្តមានតាមរយៈប្រព័ន្ធសោតទស្សន៍ពីស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

**សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**សេចក្តីសម្រេចផ្ទាល់មាត់ឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ឯកសារ E390**

អង្គជំនុំជម្រះបានស្តាប់សេចក្តីសម្រេចផ្ទាល់មាត់ ពីគ្រប់ភាគីទាក់ទងទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា (E390 ) ដើម្បីកោះហៅសាក្សី 2-TCW-1017 និងដើមបណ្តឹងរដ្ឋប្បវេណី2-TCCP-1016ទាក់ទងនឹងអង្គហេតុ មន្ទីរសន្តិសុខភ្នំក្រោល ហើយសាក្សីនេះ នឹងជំនួសសាក្សីដែលទើបទទួលមរណភាព ។ សហព្រះរាជអាជ្ញាកត់សំគាល់ថា ខ្លួនបានដាក់សំណើនេះក្រោយពីខ្លួនទទួលបានព័ត៌មានថា សាក្សី ៣ រូប ក្នុងចំណោមសាក្សី ៦ រូប ដែលនឹងត្រូវកោះហៅមកផ្តល់សក្ខីកម្ម បានទទួលមរណភាព។ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី មិនបានជំទាស់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញានោះទេ។

មេធាវីការពារក្តី នួន ជា មិនបានជំទាស់ទៅនឹងសំណើនេះទេ ប៉ុន្តែខ្លួនបានលើកឡើងថា បងប្រុសរបស់សាក្សី 2-TCW-1017 គួរតែមកផ្តល់សក្ខីកម្មក្រៅពីសាក្សី2-TCW-1017 មិនមែនក្នុងនាមជា សាក្សីជំនួសឱ្យសាក្សី 2-TCW-1017 នោះទេ។

មេធាវីការពារក្តី ខៀវ សំផន បានជំទាស់ទៅនឹងការស្នើសុំពេលវេលារបស់សហព្រះរាជអាជ្ញា ក្រោយ

ពេលចាប់ផ្ដើមសវនាការលើអង្គហេតុមន្ទីរសន្តិសុខភ្នំក្រោល។ មេធាវីការពារក្ដី ខៀវ សំផន បានលើកឡើងថា ការកោះហៅសាក្សីថ្មីនៅពាក់កណ្ដាលនៃវគ្គសវនាការ គឺនាំឱ្យមានផលប៉ះពាល់ដល់លទ្ធភាពមេធាវីការពារក្ដីដើម្បីរៀបចំ ។ មេធាវីការពារក្ដី ខៀវ សំផន ក៏បានលើកឡើងផងដែរថា តាមការវិនិច្ឆ័យពីកំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សី2-TCW-1017 មិនបានបង្ហាញនូវព័ត៌មានសមហេតុផលចំពោះប្រធានបទនេះទេ ហើយថា សាក្សី 2-TCCP-1016 ទំនងជាពុំមានព័ត៌មានពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខនោះដែរ។ ដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-1016 គួរតែមានសាក្សីបន្ថែមមកជំនួសវិញ។ មានការលើកឡើងថា ការជំទាស់របស់អង្គជំនុំជម្រះទៅនឹងការស្នើសុំរបស់សហព្រះរាជអាជ្ញា ហាក់បីដូចជាមានភាពយឺតយ៉ាវ។

ជាការឆ្លើយតបទៅនឹងមេធាវីការពារក្ដី នួន ជា សហព្រះរាជអាជ្ញាបានកត់សំគាល់ជាបឋមថា ខ្លួនមិនមានការជំទាស់ទៅនឹងការកោះហៅសាក្សី 2-TCW-1017 ដែលត្រូវជំនួសបងប្រុសរបស់គាត់ ឬ ក្រៅពីរូបគាត់នោះទេ។ ជាការឆ្លើយតបទៅនឹងការជំទាស់របស់មេធាវីការពារក្ដី ខៀវ សំផន ខាងសហព្រះរាជអាជ្ញាបានលើកឡើងថា សំណើរបស់ខ្លួនមិនមានភាពយឺតយ៉ាវទេ ក៏ប៉ុន្តែថាខ្លួនបានដាក់សំណើជាបន្ទាន់ដោយផ្អែកលើស្ថានភាពមួយដែលតម្រូវឱ្យពួកគេដើម្បីផ្លាស់ប្ដូរជាបន្ទាន់ ដូចដែលក្រុមមេធាវីការពារក្ដី បានធ្វើកន្លងមក។ សហព្រះរាជអាជ្ញាបានកត់សំគាល់ផងដែរថា ទោះបីដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-1016 មិនបានកំណត់អត្តសញ្ញាណឱ្យបានច្បាស់លាស់អំពីឈ្មោះមន្ទីរសន្តិសុខភ្នំក្រោលនេះក៏ដោយ ប៉ុន្តែទីតាំងនៃមន្ទីរសន្តិសុខនេះ ត្រូវបានបញ្ជាក់ តាមមកពីព័ត៌មានដែលមាននៅក្នុងកំណត់ហេតុនៃការស្ដាប់ចម្លើយរបស់គាត់។

**<u>សេចក្ដីសម្រេចផ្ទាល់មាត់លើសំណើរបស់សហព្រះរាជអាជ្ញា ឯកសារ E319/36</u>**

អង្គជំនុំជម្រះបានធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់លើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ E319/36 ដើម្បីទទួលយកកំណត់ហេតុនៃការស្ដាប់ចម្លើយរបស់សាក្សី 2-TCW-900 ជាឯកសារជាភ័ស្ដុតាង (E319/23.3.5) ដោយដាក់លេខឯកសារនេះ គឺ E3/9734។ សំអាងហេតុជាលាយលក្ខណ៍អក្សរសម្រាប់សេចក្ដីសម្រេចផ្ទាល់មាត់នេះ ហើយសម្អាងហេតុទៅលើផ្សេងទៀតដែលនៅសេសសល់នៃឯកសារ E319/36 នឹងជូនដំណឹងនៅពេលសមស្របខាងមុខ។

**<u>ការតាំងសំណួរទៅកាន់សាក្សី 2-TCW-900 តាមរយៈប្រព័ន្ធសោតទស្សន៍</u>**

អង្គជំនុំជម្រះ និងសហព្រះរាជអាជ្ញាអន្តរជាតិបានតាំងសំណួរទៅកាន់សាក្សី 2-TCW-900 តាមរយៈប្រព័ន្ធសោតទស្សន៍។ អង្គជំនុំជម្រះបានរំលឹកដល់ភាគីទាំងអស់ថា អនុលោមតាមឯកសារ E29/478/2 ភាគីគួរប្រើរហស្សនាមសាក្សីក្នុងអំឡុងពេលដំណើរការនីតិវិធីសវនាការ ដើម្បីការពារបូរណភាពបុគ្គល

និង ភាពសម្ងាត់នៃការស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត នាពេលបច្ចុប្បន្ន និង សុវត្ថិភាពផ្ទាល់ខ្លួនរបស់សាក្សី។

New E3s

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/10582 | E319/23.3.53.1 | 00936736-00936738, 00974007-00974010, 00970394-00970398 | Minutes of the meeting of comrades 164: Report on vessel training (Annex 1 to Written Record of Interview of PRES Mean) | P | | | |
| E3/9734 | E319/23.3.5 | 00909667-00909674; 00943559-00943566; 00986660-00986668 | Written Record of Interview of CHIN Kimthong | P | 00909669 | 00943561-00943562 | 00986662-00986663 |

**Reclassified**

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/5607 | D369/15 | 00485636-00485641; 00490559-00490564; 00520432-00520437 | Written Record of Interview of Witness SIM Sal | P | 00485638 | 00490561 | 00520434 |
| E3/5512 | D232/51 | 00401321-00401330; 00403577-00403586; 00422262-00422271 | Written Record of Interview of CHIN Kimthong, Dated 03-11-2009 | P | 00401326 00401327-00401328 | 00403582 00403583-00403584 | 00422267 00422268-00422269 |
| E3/7684 | D125/111 | 00221751-00221756; 00250070- | Written Record of Interview of KHOEM Peou | P | 00221753 | 00250072-00250073 | 00485151 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | 00250076; 00485149-00485155 | | | | | |
| E3/406 | D232/52 | 00401331-00401335; 00404075-00404079; 00422272-00422276 | Written Record of Interview of CHIN Kimthong, dated 05-11-2009 | P | 00401333 | 00404078 | 00422274 |
| E3/5605 | D369/13 | 00484142-00484146; 00488703-00488707; 00490529-00490533 | Written Record of Interview of CHIN Kimthong | P | 00484143 | 00488704 | 00488704 |

**Other documents (No Change)**

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/407 | D232/53 | 00401313-00401320; 00406220-00406227; 00422277-00422285 | Written Record of Interveiw of CHAOM Se, dated 08-11-2009 | P | 00401320 | 00406226 | 00422284 |
| E3/240 | - | 00001266-00001267; 00897667-00897668 00282550-00282551 | Ry's telegrame no 07 reported to Brother about arrested of 207 Vietnamese enemies | P | 00001266 | 00897667 | 00282550 |
| E3/1164 | D366/7.1.389 | 00052323-00052329; 00516708-00516713; 00532750-00532756 | DK-Military Report from Division 801, Political Section | P | 00052327 | 00516711 | 00532754 |
| E3/9734 | E319/23.3.5 | 00909667-00909674; 00943559-00943566; 00986660-00986668 | Written Record of Interview of CHIN Kimthong | C | 00909669 | 00943561-00943562 | 00986662-00986663 |
| E3/5512 | D232/51 | 00401321- | Written Record of | C | 00401327- | 00403583- | 00422269- |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | 00401330; 00403577-00403586; 00422262-00422271 | Interview of CHIN Kimthong, Dated 03-11-2009 | | 00401328 | 00403584 | 00422270 |
| E3/405 | D232/49 | 00401297-00401307; 00406209-00406219; 00422247-00422257 | Written Record of Interview of CHHAOM Se, dated 31-10-2009 | P | 00401300 00401304-00104305 | 00406213-00406214 00406216 | 00422250-00422251-00422255 |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.១០)
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.00 ព្រឹក នៅថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៦។ (១៦.០៩)

**<u>កាលវេលាសវនាការបន្ត</u>**

សវនាការនឹងបន្តទៅថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៦ ចាប់ផ្តើមពីម៉ោង ០៩.00 ព្រឹក។

ភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ឯម ហ៊ិយ** Ma[illegible] McCARTHY